

NAGAWORLD®
金界

**For immediate release:**
1st September 2017

# NAGAWORLD REWARDS CAMBODIA'S SEA GAMES CHAMPIONS

**Phnom Penh, Cambodia 1st September 2017 -** NagaWorld hosted a special reward ceremony for the Cambodian champions of the 29th SEA Games as part of *Go For Gold* partnership with the National Olympic Committee of Cambodia (NOCC). The prestigious event was held at NagaCity Walk, the underground duty free shopping at NagaWorld, which was attended by key NOCC officials including Secretary General H.E. Vath Chamroeun, athletes, media, and NagaWorld's senior management.

Petanque Doubles' winners, Miss Ke Leng and Miss Ouk Sreymom were awarded US$5,000 for Team Gold, while Mr. Khun Dima (Men's Muay 63kg) and Miss Sorn Seavmey (Female Taekwondo Under 73kg) were awarded US$3,000 each for Individual Gold medals. NagaWorld contributed an additional US$1,500 to NOCC, representing US$500 for each gold medal achieved by the Cambodian contingent. In total, the Cambodian contingent achieved 3 Gold, 2 Silver and 12 Bronze medals, surpassing the record achieved in the last SEA Games.

Executive Director of NagaWorld, Mr. Pern Chen reiterated, "Looking at the significant milestones achieved by our national athletes over the years, we are confident they will continue to shine on the world stage. It is our great honour to be part of this meaningful journey together with NOCC in promoting the sports development for the country". In partnership with NOCC, NagaWorld is committed in supporting Cambodia contingent in major international sports events such as the Olympics, SEA Games and Asia Games until 2018.

**NagaWorld Empowering Sports**

Nagaworld is the first company in the country's corporate sector to sign an alliance with the NOCC to support the Cambodian contingent for the 2011 SEA Games in Indonesia and London 2012 Olympics. NagaWorld subsequently signed a 4 year agreement with the NOCC in 2015 for major international sports events including the Olympics, SEA Games and Asia Games until 2018.

NagaWorld has also contributed in supporting kick boxing, tennis, football and mixed martial arts among other sports, helping to raise the profile and development of Cambodian sports, and encourage the participation of athletes on a national and regional level, leading the path to succeed on the international stage.

Since 2016, NagaWorld has hosted the annual Cambodian Sports Awards with NOCC at its hotel venue, acknowledging Cambodian athletes, coaches and media for their distinguished success in the sports arena.

**XXX**



**About NAGAWORLD®**

Stay, play, dine, shop and meet at NagaWorld®, the entertainment centre of the Mekong.

NagaWorld® is strategically sited in the vibrant capital city of Cambodia, amidst the picturesque terrain of the Mekong and Tonlé Sap Rivers, in the iconic economic hub of Phnom Penh.

NagaWorld®, Phnom Penh is the first and best-in-class integrated hotel and entertainment complex in Cambodia, and is the recipient of numerous international awards in the hospitality and tourism sector. It is owned by the holding company – NagaCorp, which is listed on the Hong Kong Stock Exchange.

With the latest expansion, NagaWorld consists of 1,658 rooms, 27 Food & Beverage outlets and clubs, an all-suite luxurious spa, shopping gallery including China Duty Free Group, the first underground shopping centre in Cambodia selling luxurious international brands, extensive entertainment services including gaming facilities, premium meeting spaces with state-of-the-art facilities, as well as one of the country's largest MICE facilities that accommodates more than 1,000 delegates and a sophisticated brand new 2,000-seat theatre opening soon.

**For media enquiries or photos, please contact:**


| | |
|---|---|
| Ms. Melanie Loong<br>Senior Marketing Communications Manager<br>Tel: (+855) 10 737 684<br>Email: melanieloong@nagaworld.com | Ms. Phouk Solinda<br>Brand Executive<br>Tel: (+855) 15 618 886<br>Email: phouksolinda@nagaworld.com |



NAGAWORLD®
金界

សម្រាប់ចុះផ្សាយបន្ទាន់
ថ្ងៃទី ១ កញ្ញា ២០១៧

# ណាហ្គាវើលដ៍ ផ្តល់រង្វាន់ដល់អត្តពលិកជើងឯកស៊ីហ្គេមកម្ពុជា

**រាជធានីភ្នំពេញ ថ្ងៃទី ១ កញ្ញា ២០១៧ ៖** ណាហ្គាវើលដ៍ បានរៀបចំពិធីប្រគល់រង្វាន់ដល់អត្តពលិកជើងឯកកម្ពុជានៃព្រឹត្តិការណ៍កីឡាស៊ីហ្គេមលើកទី ២៩ ជាផ្នែកមួយនៃយុទ្ធនាការ "ដំណើរឆ្ពោះទៅរកមេដាយមាស" ដែលណាហ្គាវើលដ៍បានសហការជាមួយគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា។ កម្មវិធីទទួលស្វាគមន៍ និងប្រគល់រង្វាន់នេះ ត្រូវបានធ្វើឡើងនៅផ្សារទំនើបក្រោមដីណាហ្គាស៊ីធីវ៉កដែលជាផ្សារទំនើបក្រោមដីលក់ទំនិញរួចពន្ធនៅណាហ្គាវើលដ៍ដែលមានការចូលរួមពីឯកឧត្តមវ៉ាត់ ចំរើន អគ្គលេខាធិការនៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា អត្តពលិក មិត្តសារព័ត៌មាន និងគណៈគ្រប់គ្រងជាន់ខ្ពស់ណាហ្គាវើលដ៍។

កីឡាការិនីមេដាយមាស កែ ឡេង និងអ៊ុក ស្រីមុំ ទទួលបានរង្វាន់ ៥.០០០ (ប្រាំពាន់)ដុល្លារអាមេរិកក្នុងវិញ្ញាសាប៉េតង់វាយគូនារី ។ កីឡាករមេដាយមាសប្រដាល់គុនខ្មែរទម្ងន់ ៦៣ គីឡូក្រាម ឃឹម ឌីម៉ា និងកីឡាការិនីមេដាយមាសតៃក្វាន់ដូទម្ងន់ក្រោម ៧៣ គីឡូក្រាម ទទួលបាន ៣.០០០ (បីពាន់)ដុល្លារអាមេរិកក្នុងម្នាក់ៗក្នុងវិញ្ញាសាឯកត្តជន។ ណាហ្គាវើលដ៍ក៏បានឧបត្ថម្ភផងដែរដល់គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជានូវទឹកប្រាក់ ១.៥០០ (មួយពាន់ប្រាំរយ)ដុល្លារអាមេរិកសម្រាប់មេដាយមាសនីមួយៗដែលអត្តពលិកកម្ពុជាទទួលបាន ដែលមេដាយមាសនីមួយៗស្មើនឹងទឹកប្រាក់ ៥០០ (ប្រាំរយ)ដុល្លារអាមេរិក។ សរុបរួម កម្ពុជាទទួលបានមេដាយមាស ៣ មេដាយប្រាក់ ២ និងមេដាយសំរឹទ្ធ ១២ ដែលបានបំបែកឯតទគ្គកម្មកាលពីស៊ីហ្គេមកាលពី ២ ឆ្នាំមុន។

នាយកប្រតិបត្តិក្រុមហ៊ុនណាហ្គាវើលដ៍ លោក Pern Chen បានមានប្រសាសន៍អះអាងជាថ្មីថា "ដោយមើលឃើញស្នាដៃឆ្នើមដែលអត្តពលិកកម្ពុជាទទួលបានក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ យើងជឿជាក់ថាពួកគេនឹងបន្តស្នាដៃដ៏ល្អនេះជាបន្តទៀតនៅលើឆាកអន្តរជាតិ។ វាពិតជាមោទនភាពដ៏អស្ចារ្យរបស់ណាហ្គាវើលដ៍ផងដែរដែលបានក្លាយជាផ្នែកមួយនៃភាពជោគជ័យនេះជាមួយគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជាក្នុងការជួយលើកកម្ពស់ និងអភិវឌ្ឍវិស័យកីឡាសម្រាប់ប្រទេសកម្ពុជា"។ ណាហ្គាវើលដ៍ប្តេជ្ញាបន្តឧបត្ថម្ភគាំទ្រដល់គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជាក្នុងព្រឹត្តិការណ៍កីឡាអន្តរជាតិ



NAGAWORLD®
金界

ដូចជាព្រឹត្តិការណ៍កីឡាអូឡាំពិក ស៊ីហ្គេម និងអាស៊ានហ្គេម (ឬព្រឹត្តិការណ៍កីឡាទ្វីបអាស៊ី) រហូតដល់ឆ្នាំ ២០១៨ ។

**ណាហ្គាវើលដ៍ជួយលើកកម្ពស់ និងអភិវឌ្ឍវិស័យកីឡាក្នុងប្រទេសកម្ពុជា ៖**
ណាហ្គាវើលដ៍ គឺជាក្រុមហ៊ុនឯកជនទី ១ ក្នុងព្រះរាជាណាចក្រកម្ពុជាដែលបានចុះហត្ថលេខាជាមួយគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជាដើម្បីឧបត្ថម្ភដល់អត្តពលិកកម្ពុជាក្នុងព្រឹត្តិការណ៍កីឡាស៊ីហ្គេមក្នុងប្រទេសឥណ្ឌូនេស៊ីឆ្នាំ ២០១១ និងព្រឹត្តិការណ៍កីឡាអូឡាំពិកក្នុងទីក្រុងឡុងដ៍ប្រទេសអង់គ្លេសឆ្នាំ ២០១២ ។ បន្ទាប់មក ណាហ្គាវើលដ៍បានចុះកិច្ចព្រមព្រៀងរយៈពេល ៤ ឆ្នាំជាមួយគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជាក្នុងឆ្នាំ ២០១៥ ដើម្បីជួយឧបត្ថម្ភអត្តពលិកកម្ពុជាក្នុងព្រឹត្តិការណ៍កីឡាអន្តរជាតិដែលរួមមានព្រឹត្តិការណ៍កីឡាអូឡាំពិក ស៊ីហ្គេម និងអាស៊ានហ្គេមរហូតដល់ឆ្នាំ ២០១៨ ។

មិនត្រឹមតែប៉ុណ្ណោះ ណាហ្គាវើលដ៍ក៏បានជួយឧបត្ថម្ភផងដែរដល់កីឡាប្រដាល់សេរីគុនខ្មែរ តេនីស បាល់ទាត់ និងការប្រកួតក្បាច់គុនចម្រុះដើម្បីជួយលើកកម្ពស់កិត្តិស័ព្ទ និងអភិវឌ្ឍវិស័យកីឡានៅកម្ពុជាព្រមទាំងលើកទឹកចិត្តឲ្យមានការចូលរួមកាន់តែច្រើនរបស់អត្តពលិកកម្ពុជាក្នុងការប្រកួតកម្រិតជាតិ និងតំបន់ ដើម្បីឈានដល់ការប្រកួតលើឆាកអន្តរជាតិ។

គួររំឭកផងដែរថា ចាប់តាំងពីឆ្នាំ ២០១៦ ណាហ្គាវើលដ៍បានរៀបចំកម្មវិធីប្រគល់ពានរង្វាន់កីឡានៅសណ្ឋាគាររបស់ខ្លួនជាមួយគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ដែលកម្មវិធីនេះជាកម្មវិធីដែលទទួលស្គាល់អត្តពលិកកម្ពុជា គ្រូបង្វឹក និងសារព័ត៌មានកីឡាដែលមានស្នាដៃឆ្នើមក្នុងវិជ្ជាជីវៈរបស់ខ្លួន។

**<u>អំពីណាហ្គាវើលដ៍®</u>**

ស្នាក់នៅ កម្សាន្ត ស្រស់ស្រូប ទិញទំនិញ និងប្រជុំនៅណាហ្គាវើលដ៍ មណ្ឌលកម្សាន្តប្រចាំតំបន់ទន្លេមេគង្គ។

ណាហ្គាវើលដ៍ ស្ថិតនៅទីតាំងយុទ្ធសាស្ត្រក្នុងរាជធានីនៃប្រទេសកម្ពុជាដែលមានទេសភាពស្រស់ត្រកាលទាក់ទាញនៅជាប់ទន្លេមេគង្គ និងទន្លេសាប និងជាមជ្ឈមណ្ឌលសេដ្ឋកិច្ចមួយក្នុងរាជធានីភ្នំពេញ។

NagaWorld, Samdech Techo Hun Sen Park, Phnom Penh,
Kingdom of Cambodia. P.O. Box 1099 Phnom Penh
t +855 23 22 88 22 f +855 23 21 03 94
enquiries@nagaworld.com www.nagaworld.com



ណាហ្គាវើលដ៍ភ្នំពេញ គឺជាសណ្ឋាគារ និងមណ្ឌលកម្សាន្តឈានមុខគេក្នុងប្រទេសកម្ពុជាដែលទទួលបានពានរង្វាន់អន្តរជាតិជាច្រើនក្នុងវិស័យបដិសណ្ឋារកិច្ច និងទេសចរណ៍។ ណាហ្គាវើលដ៍ ត្រូវបានគ្រប់គ្រងដោយក្រុមហ៊ុនណាហ្គាខបដែលជាក្រុមហ៊ុនមេដែលបានចុះបញ្ជីក្នុងទីផ្សារភាគហ៊ុនហុងកុង។

ជាមួយការពង្រីកបន្ថែមថ្មីចុងក្រោយ ណាហ្គាវើលដ៍ មានបន្ទប់ប្រភេទស្វីត និងដីលុច្សជាង ១៦៥៨ បន្ទប់ជាមួយការបើកដំណើរការអាគារសាខាថ្មី ភោជនីយដ្ឋាន និងក្លឹប ២៧ កន្លែង មណ្ឌលស្ប៉ាដ៏ប្រណីត ហាងលក់ទំនិញរួចពន្ធ រួមមានក្រុមហ៊ុន China Duty Free Group ដែលជាផ្សារទំនើបក្រោមដីទីមួយក្នុងប្រទេសកម្ពុជាដែលមានលក់ទំនិញម៉ាកអន្តរជាតិល្បីៗ សេវាកម្សាន្តសម្បូរបែប រួមមានកាស៊ីណូ សាលប្រជុំបំពាក់ទៅដោយបរិក្ខារទំនើបៗ និងជាសណ្ឋាគារដែលមានសាលសន្និសីទធំជាងគេក្នុងព្រះរាជាណាចក្រកម្ពុជាដែលអាចទទួលប្រតិភូច្រើនជាង ១.០០០ នាក់ និងរោងកុនដែលមានកៅអីប្រមាណ ២.០០០ ដែលនឹងបើកដំណើរការក្នុងពេលឆាប់ៗនេះ។

សម្រាប់សំណួរទាក់ទងការផ្សព្វផ្សាយ ឬរូបថត សូមទាក់ទង ៖

| | |
|---|---|
| Ms. Melanie Loong<br>Senior Marketing Communications Manager<br>Tel: (+855) 10 737 684<br>Email: melanieloong@nagaworld.com | Ms. Phouk Solinda<br>Brand Executive<br>Tel: (+855) 15 618 886<br>Email: phouksolinda@nagaworld.com |

NagaWorld, Samdech Techo Hun Sen Park, Phnom Penh,
Kingdom of Cambodia. P.O. Box 1099 Phnom Penh
t +855 23 22 88 22 f +855 23 21 03 94
enquiries@nagaworld.com www.nagaworld.com